D119568 DC-Cam

# របាយការណ៍
# ស្តីពីការចុះទៅសិក្សាស្រាវជ្រាវ
# ធ្វើផែនទីរណ្តៅសាកសពជនរងគ្រោះ
# ដោយរបបខ្មែរក្រហម
# នៅខេត្តកំពង់ឆ្នាំង

**ថ្ងៃទី ២៣-៦-៩៨**

**ខេត្តកំពង់ឆ្នាំង**

កាលពីថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៨ មជ្ឈមណ្ឌលស្រាវជ្រាវឯកសារកម្ពុជា បានចាត់តាំង ដោយ លោក **ស៊ុន ឃិន** និងលោក **អ៊ូច សំអឿន** ចុះទៅខេត្តកំពង់ឆ្នាំង ។

នៅម៉ោង ៨:១០ នាទី ក្រុមស្រាវជ្រាវយើងបានទៅដល់សាលាខេត្តកំពង់ឆ្នាំង ដោយធ្វើដំណើរ តាមផ្លូវជាតិលេខ ៥ ពីទីក្រុងភ្នំពេញ ទៅខេត្តកំពង់ឆ្នាំង ។ ចំងាយផ្លូវ ៩១ គីឡូម៉ែត្រ ។

នៅសាលាខេត្ត យើងជួបមន្ត្រីការិយាល័យរបៀបរួចមក យើងបានទៅជួបឯកឧត្តម **ឡេង លឿង** អភិបាលរងទី ៣ សំណេះសំណាល និងទំនាក់ទំនងការងារ ក្រុមយើងបានជំរាបអំពីគោលបំណង និងសំណូម ពរការងារ ។

**<u>គោលបំណង:</u>** មជ្ឈមណ្ឌលស្រាវជ្រាវឯកសារកម្ពុជា មានបំណងចុះមកខេត្តកំពង់ឆ្នាំ សុំការ អនុញ្ញាតអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ អង្គភាពពាក់ព័ន្ធ ពីខេត្តទៅស្រុក និងឃុំ ភូមិ និងប្រជារាស្ត្រ ដើម្បីងាយស្រួលក្នុងការបង្កការងាយស្រួលស្របច្បាប់ និងធានានូវសន្តិសុខ ប្រយោជន៍សំរេចលទ្ធផល ការងារ ។

**<u>សំណូមពរ:</u>** ចង់បានទីតាំង គុក សន្តិសុខ កន្លែងសម្រាប់ រណ្តៅសាកសព ប្រយោជន៍ចុច Computer និងសាកសួរបំភ្លឺបញ្ហាខ្មែរក្រហម ទូទាំងខេត្តកំពង់ឆ្នាំង ។

<u>ម៉ោង ៩:១០ នាទី</u>

បន្ទាប់មកទៀត យើងទៅមន្ទីរវប្បធម៌វិចិត្រសិល្បៈខេត្ត ជួបលោក :

១- លោក **លី សុធី** ប្រធានការិយាល័យវប្បធម៌ខេត្ត

២- លោក **ហ៊ុន សុខុម** ប្រធានការិយាល័យរដ្ឋបាល

**<u>អំពីពត៌មាន និងឯកសារ</u>**

នៅទីនេះយើងបានឯកសារសរសេរដៃដោយលោក **លី សុធី** ឯកសារស្តីអំពីអំពើប្រល័យពូជ សាសន៍របបខ្មែរក្រហមទូទាំងខេត្តកំពង់ឆ្នាំង មានទីតាំងគុកសន្តិសុខ សម្ងាប់នៅទូទាំងស្រុក ចំណុះខេត្ត (ងាយស្រួល) ។ (យើងចំណេញពេលវេលា)

បន្ទាប់មកយើងទៅជួបលោកអនុសេនីយត្រី **សេក ថ្មឹន** អនុប្រធានទី១ សេនាធិការនគរ បាល ខេត្តកំពង់ឆ្នាំង យើងសុំចំណារលាយលក្ខណ៍អក្សរពីគាត់ ប្រយោជន៍ទៅទាក់ទងអធិការដ្ឋាននគរបាល ទូទាំងស្រុក ក្នុងខេត្តកំពង់ឆ្នាំង ។

**ម៉ោង ១០:៣០ នាទី**

## I- <u>ស្រុកបរិបូរណ៌</u>

នៅទីនេះយើងបានធ្វើដំណើរចេញពីខេត្ត តាមដងផ្លូវជាតិលេខ ៥ ចំងាយពីសាលាខេត្តដល់សាលា ស្រុកបរិបូរណ៌ ៣២ គីឡូម៉ែត្រ ។

នៅទីនេះសាលាស្រុកគ្មានមន្ត្រីម្នាក់ទេ ដូច្នេះយើងទៅជួបលោកអធិការរងនគរបាលស្រុកបរិ បូរណ៌ ទំនាក់ទំនងការងារសន្តិសុខ និងពត៌មានផ្សេងៗ ។

**<u>ពត៌មានសន្តិសុខ</u>**

ក្នុងស្រុកបច្ចុប្បន្ន មានចោរប្លន់គោក្របី នៅតាមជនបទ (ពីមុនមានចាប់ជីវិត) ។

ស្ថានភាពសន្តិសុខមធ្យម ។

**<u>ពត៌មានទាក់ទងទីតាំងប្រល័យពូជសាសន៍</u>**

អនុប្រធានអធិការដ្ឋាននគរបាល បានអោយយើងដឹងថា នៅស្រុកបរិបូរណ៌មានទីតាំងដូចតទៅ :

**<u>១- សន្តិសុខ គុកធំ កន្លែងសម្ងាប់</u>**

ស្រុក ១០ ជំនាន់ប៉ុល-ពត តំបន់ ៣១ ភូមិភាគបច្ចឹម គឺតាំងនៅវត្តសម្តេច **មុនី** ហៅ សម្តេច **គុក** ។

**<u>២- សារៈមន្ទីរ</u>** ឬ បូជនីយដ្ឋានតំកល់អដ្ឋិធាតុជនរងគ្រោះដោយរបបខ្មែរក្រហម នៅវត្តនេះដែរ ទីតាំងសម្ងាប់មាន :

- នៅក្នុងវត្ត ខាងជើងព្រះវិហារ
- នៅព្រៃស្រែហែក ព្រៃរូងខ្លា

} សម្ងាប់ឆ្នាំ ១៩៧៥

ទីតាំងនេះឋិតនៅក្នុងឃុំពេលចង្វា

នៅមន្ទីរពេទ្យស្រុក ចំងាយពីមន្ទីរពេទ្យ ៧០០ម៉ែត្រ។ ពត៌មានបន្ថែមអធិការរងស្រុកបានឲ្យ យើងចុះទៅជួបលោកគា **ហាន់ សារិន** ឌុពុក អភិបាលរងស្រុក គាត់ជាគណៈឃុំឆ្នាំ ១៩៧៩ និងគណៈ កម្មការវត្ត និងទៅរកលោកតាឈ្មោះ **ស៊ុន ចាន់** ជាគណៈកម្មការវត្តសម្តេចមុនីនេះ ស្រង់ពត៌មានលំអិត និងជាក់ស្តែង ព្រោះគាត់ទាំងពីរនៅទីតាំងនេះស្រាប់ពីមុនៗ គាត់អាចដឹងច្បាស់ជាង ។ (ភូមិដក់ពរ ឃុំដក់ពរ) ។

**<u>ម៉ោង ១១:១០ នាទី</u>**

ជួបអភិបាលស្រុកនៅផ្ទះ

យើងចង់បានពត៌មានបន្ថែម និងចង់បានការអនុញ្ញាតច្បាប់ចុះស្រុកបរិបូរណ៍ទូទាំងឃុំ ភូមិ ដូច្នេះ ចាំបាច់ជួបលោក **ញឹក គឿន** អភិបាលស្រុក ។

**<u>អំពីឥតិមានពីទៅហ្វាយស្រុក</u>**

ទៅហ្វាយស្រុក គាត់ក្តោបក្តាប់ការងារនេះមិនសូវច្បាស់ដែរ ព្រោះគាត់សម័យប៉ុល-ពត មិននៅ ទីនោះទេ គាត់បង្ហាញយើងទៅជួបលោកគា ២នាក់ ដូចលោកអធិការរងប្រាប់យើង ។

<u>យើងចង់ដឹង :</u>

លក្ខណៈទីតាំង និងភូមិសាស្ត្រស្រុក

- ខាងជើង ទល់នឹងស្រុកត្រកូល ខេត្តពោធិសាត់
- ខាងត្បូង រលាប្អៀរ ខេត្តកំពង់ឆ្នាំង
- ខាងលិច ដងព្រៃគុបត្រកូល ខេត្តពោធិសាត់
- ខាងកើត ដងទន្លេសាប ជារាយ ខេត្តកំពង់ធំ ។

☐ សម័យប៉ុល-ពត ស្រុក ១០ តំបន់ ៣១ ភូមិភាគបច្ចឹម ។

☐ ជាតំបន់រាលរាប សម្បូរព្រៃឈើ ព្រៃរបោះ ព្រៃរនាម អូរ ស្ទឹង បឹង ។

☐ មុខរបរប្រជាជន ធ្វើស្រែ ចំការ នេសាទ អូស ធ្យូង ។

ក្រោយពីបានពត៌មានប្រយោលរួចហើយ យើងចុះទៅសួរនាំអ្នកដឹងព្រឹត្តិការណ៍ដូចដែល យើងដឹងតាមរយៈអធិការដ្ឋាននគរបាល និង ឯកសារវប្បធម៌ខេត្ត ។

**<u>ម៉ោង ១១:៣០ នាទី</u>**

យើងបានមកដល់ទីតាំង :

<u>សន្តិសុខ គុក កន្លែងសម្លាប់ វត្តសម្តេច **មុនី**</u>

ទីនេះចំងាយពីសាលាស្រុក ១,៥០គីឡូម៉ែត្រ ទៅ ២គីឡូម៉ែត្រ ឋិតនៅទិសខាងកើតសាលាស្រុក ឈៀងខាងត្បូង បត់ស្តាំដៃ បើចេញពីសាលាស្រុក ចូលជ្រៅទៅកាន់វត្ត ២ (ពីរ) វត្តគ្រួស និងវត្តដក់ពរ រួចឆ្ពោះទៅវត្តសម្តេចមុនី (សម្តេចតុក) ២ គីឡូម៉ែត្រ ។

នៅទីវត្តនេះ យើងបានជួបលោកតា **ស៊ុន ចាន់** គណៈកម្មការវត្ត បច្ចុប្បន្ននៅភូមិដក់ពរ ឃុំខុនរ៉ង ស្រុកបរិបូរណ៍ ។ លោកតាអាយុ ៧៣ឆ្នាំ ។ សម័យប៉ុល-ពត កងដឹកជញ្ជូនភស្តុភា ស្បៀង ។ ក្រោយឆ្នាំ ១៩៧៩ មេឃុំនៅឃុំខុនរ៉ងនេះ ។

**<u>អំពីឧត្តមានលំអិត</u>**

លោក **ស៊ុន ចាន់** ជាសាក្សីដ៏សំខាន់ម្នាក់ គាត់បានប្រាប់យើងដោយគ្មានលាក់លៀមថា :

គាត់បានដឹងច្បាស់ថា ទីវត្តសម្តេចមុនី សម្តេចតុក ជាគុក+សន្តិសុខ និងកន្លែងសម្លាប់ដ៏ធំរបស់ ស្រុក១០ សម័យប៉ុល-ពត (សព្វថ្ងៃស្រុកបរិបូរណ៍) ។ (ឃុំអញ្ចាញ្ជរូង) ទីតាំងនេះពួកខ្មែរក្រហមយក :

ក- វិហារជាគុក

ខ- កុដិ ២ ប្រក់ក្បឿង ខាងក្រោយវិហារជាគុក

គ- កុដិធំ ១ ជ្រុងខាងជើងវិហារជាកន្លែងសួរចម្លើយ

***- ទីតាំងសម្លាប់***

ក- ខាងជើងព្រះវិហារ ចំងាយ ៥០ ម៉ែត្រ មានរណ្តៅប្រហែល ១០០រណ្តៅ ក្នុង ១រណ្តៅ ១៣នាក់ ទៅ ១៥ នាក់ ។

ខ- ព្រៃគោកល្វា ១ គីឡូម៉ែត្រ ពីវត្តតុក ខាងជើងវត្ត

គ- ព្រៃគោកជ្រៃតំ ១,៥ គីឡូម៉ែត្រ ពីវត្ត ខាងជើង

ឃ- ភូមិត្នោតជោ (ភូមិចាស់) ៥០០ ម៉ែត្រ ពីវត្ត

ង- ព្រៃពោធិតាង៉ា ១ គីឡូម៉ែត្រ ពីវត្ត (ទិសខាងជើង)

ហ- ព្រៃពោធិចារ្យ ព្រៃពោធិតាមឿន ព្រៃពោធិតាកុយ ក្បែរៗគ្នាចំងាយ ២ គីឡូម៉ែត្រ ទិសខាង ជើងវត្តសម្តេចមុនីទាំងអស់

ឆ- ព្រៃតានៃយ (ព្រៃខ្មោច) ទួលខ្ពស់៦គីឡូម៉ែត្រ ។ (ពីវត្តឆ្ងាយ គ្មានផ្លូវព្រៃ) ។

ពត៌មានពី **ស៊ុន ចាន់** បន្ថែម មេខ្មែរក្រហម មេគុក សន្តិសុខ ឈ្មោះ អា**ស្ងួន** រស់នៅ ផ្ទះថ្ម ខាងលិចវត្តចំងាយ ២០០ម៉ែត្រ ទៅ ៣០០ម៉ែត្រ ផ្ទះក្រែ **លឹម**(ស្លាប់) ។ (អាស្ងួនបាត់ខ្លួនហើយ) ។

**<u>អំពីរណ្តៅសាកសព</u>**

សាក្សីបានប្រាប់យើងថា រណ្តៅក្បែរវិហារ សម្លាប់ទម្លាក់ ដោយសួរចម្លើយ ដោយវៃ ដោយឈឺ ដោយអត់បាយ ទីនេះ ១០០ រណ្តៅ។ អ្នកស្លាប់ប៉ាន់ស្មានប្រហែលពី ៨០០នាក់ ទៅ ១៣០០ នាក់ ។

- <u>សម្លាប់សរុបរួម</u> ៣២,០០០ នាក់ សាក្សី **ម៉ាន់ សារិន** រើសបានឯកសារសរសេរដៃ ដោយពួកខ្មែរក្រហមបន្សល់ទុកឆ្នាំ ១៩៧៩-៨០ គាត់បានឃើញក្រដាសពេលចូលដល់ ១៩៧៩-៨០ <u>ដាក់ថាកំទេចបាន ៣២,០០០ នាក់</u> នៅគុក សន្តិសុខ កន្លែងសម្លាប់ វត្តសម្តេចតុក សម្តេចមុនីនេះ ។

- ឯកសារប្រគល់ជូន តា **ស៊ុន ច៉ាន់** អតីតៈមេឃុំសម័យនោះ គាត់មិនបានចាប់អារម្មណ៍រក្សា ទុក (ជាតំបង់) ។

- ប្រភេទជនរងគ្រោះជាប់គុក សម្លាប់នៅទីនោះ សាក្សី **ស៊ុន ច៉ាន់** សាក្សី **ម៉ាន់ សារិន** បំភ្លឺច្បាស់ជ្រាប់យើងទៀតថា :

  - នៅឆ្នាំ ១៩៧៥ និងដើមឆ្នាំ ១៩៧៦ ពួកអ្នកដំលៀសចេញពីទីក្រុងនានា ដូចជាពី ភ្នំពេញ កំពង់ឆ្នាំង និងពីពោធិសាត់ ជាតំបង ឲ្យតែដើរឆ្លងកាត់ សន្តិសុខគុកនេះ ចាប់បញ្ចូលទីនេះទាំងអស់ ។ ដំបូងបញ្ចូលគុកវត្តគ្រួស វត្តនេះវិហារមិនសូវមាំទាំ គេ បញ្ចូលមកវត្តសម្តេចមុនីនោះ ។
  - នៅដើមឆ្នាំ ១៩៧៦ ចុង និងដើមឆ្នាំ ១៩៧៧ - ៧៨ អ្នកខុសសីលធម៌ផ្សេងៗ តាមសហករណ៍ ឃុំនានា ទូទាំងស្រុក១០ (ស្រុកបរិបូរណ៍) យកមកទីនេះ អ្នកខុស ឆ្គងនិន្នាការ គេចោទថា ភ្នាក់ងារបង្កប់ ។ល។ និយាយរួមអោយតែឆ្លងកាត់ទីនេះ ចាប់បញ្ចូលទាំងអស់ ។

នៅចុងភូមិខាងកើតមាត់ទន្លេជាកំពង់ចម្លងមកពីឆ្នុកទ្រូ ពោធិសាត់ ជារាយណ៍កំពង់ធំ កំពង់ឆ្នាំង ។ល។ ពេលអ្នកដឹះទូកក្តី ឲ្យតែឡើងគោកនៅទីនេះ ពួកឃាតករចាប់បញ្ចូលគុក រួចរៃចោលទាំងអស់ ។ សាក្សី **ម៉ាន់ សារិន** បន្ថែមថា រណ្តៅប្រឡាយដ៏ធំមុខវត្ត ពីលិចទៅកើត ពីជើងទៅត្បូង ពួករៃ សម្លាប់ទម្លាក់ពេញៗទាំងអស់ គាត់ឃើញពេលចូលដល់ឆ្នាំ ១៩៨០ ។

<u>សាក្សីទាំងពីរបន្ថែមទៀតថា :</u>

ឧរុណាកម្ម ជាធ្វើចំពោះជនរងគ្រោះ ដុតទាំងរស់ ចងដើងព្យួរ ទម្លាក់ចូល អាងទឹក ពាងទឹក ធ្វើដូចទួលស្លែង ជាក់ស្តែងអ្នកធ្លាប់ជាប់គុកនៅទីនោះ ហើយនៅរស់ គឺ :

១- អ្នកមីង **អាយ យ៉ិន** សព្វថ្ងៃនៅភូមិត្រពាំងពោធិ ឃុំខុនរ៉ង ស្រុកបរិបូរណ៍ ។

២- លោកស្រី **ផល** បច្ចុប្បន្នពេទ្យស្រុកបរិបូរណ៍ ។

៣- លោកស្រី **ប៊ូ** រស់នៅភូមិ - ឃុំ - ស្រុក ដូចខាងលើ ។

- ទាំង ៣ នាក់ នេះជាប់គុកនៅទីនោះផ្ទាល់
- ឯកសារគួបជ្រុំ
- ថតសាក្សី ២ នាក់
- ថតវិហារ កុដិ ជាគុក
- ថត ចេតីយ ដាក់អដ្ឋិធាតុ
- សម្ភាសន៍សាក្សីទាំង ២ នាក់

ដូច្នេះពត៌មានលំអិតនៅក្នុងការសែតថែមទៀត ទុកឯកសារ ។

<u>ម៉ោង ១៤:០០</u>

ក្រុមយើងត្រឡប់ទៅជួបសាក្សី **មាន់ សារិន** សួរកឯកសារសរសេរដៃ ដែលគាត់រើសបាន ឯកសារសរសេរថា កំទេចបាន ៣២,០០០នាក់ ហើយឯកសារនេះបាត់ (មេឃុំធ្វើបាត់) ។ (សម្ភាសន៍រួច)

<u>ម៉ោង ១៤:៣០ នាទី</u>

- យើងជិះរទេះសេះសំដៅទៅទីតាំង :
- ភូមិត្នោតជោ (ភូមិចាស់) ៥០០ ម៉ែត្រ ពីវត្តសម្តេចមុនី
- ព្រៃពោធិតាង៉ា ១,០០០ ម៉ែត្រ ពីវត្តសម្តេចមុនី
- ព្រៃពោធិតាចារ្យ ២,០០០ ម៉ែត្រ ពីវត្តសម្តេចមុនី

+ ទីតាំងនេះនៅជិតៗគ្នា ចំងាយ ពី ៥០០ ម៉ែត្រ ទៅ ៦០០ម៉ែត្រ

+ យើងថតអ្នកបរទេះសេះចង្អុលទីតាំងទាំង នេះ

+ ថតមន្ត្រីវប្បធម៌ខេត្ត រួមដំណើរចង្អុលទីតាំងនោះ

នៅទីតាំងនោះ កន្លែងសម្រាប់នៅខាងជើងវត្ត ឈៀងខាងកើត ជាតំបន់ព្រៃរបោះ មានដើមពោធិ សំគាល់ ដើមស្នោត (ថតឯកសាររួច) ។

ទីតាំងសម្រាប់ដែរ ប៉ុន្តែមិនបានទៅដល់

មូលហេតុ:

- គ្មានផ្លូវ សុទ្ធតែព្រៃ
- សន្តិសុខមិនសូវល្អ ចោរប្លន់ប្រដាប់អាវុធ
- ឆ្ងាយផុតផ្ទះប្រជាជន ស្ងាត់ណាស់

ទីនោះគឺ

- ព្រៃគោកជ្រវត់
- ព្រៃគោកល្វា + ព្រៃតាន័យ (ព្រៃខ្ចោច)

ទីតាំងខាងលិចផ្លូវ ទួលភ្នំ

- ព្រៃរួងភ្នា ព្រៃសុទ្ធសាធ គ្មានផ្លូវទៅឡើយ (ភ្នាំង)

**<u>សេចក្តីបញ្ជាក់</u>**

នៅទីតាំងសម្រាប់នីមួយៗ រណ្តៅជាត់បង់លុបអស់ទៅជាវាលស្រែ ព្រៃដុះ ។ យើងបានកត់ឈ្មោះ សាក្សីនាំទៅដល់ទីតាំង **រិន សៅអ៊ឹម** អាយុ ១៩ឆ្នាំ ។ ក្រុមយើងបានទៅទីតាំងឆ្ងាយមុន រួចត្រឡប់មក ក្រោយវិញ ដល់ម៉ោង ១៦:០០នាទី ។ មកដល់ខេត្តកំពង់ឆ្នាំងនៅម៉ោង ១៧:០០ ។

**<u>សេចក្តីសន្និដ្ឋានផ្ទាល់</u>**

នៅស្រុកបរិបូរណ៍នេះ ទីតាំងសម្រាប់ដ៏ធំ ហើយសម្រាប់ច្រើន ៣២,០០០ នាក់ សាក្សី ២នាក់ បានឃើញឯកសារសាក្សីផ្ទាល់ភ្នែក ឃើញគុក សន្តិសុខ ឯកន្លែងសម្រាប់ ក្រោយឆ្នាំ ១៩៧៩ សាក្សី **ស៊ុន ច័ន** បានដឹកស្បៀងមកក្បែរៗវត្ត ។ ក្នុងសម័យ **ប៉ុល ពត** គាត់ជាកម្មាភិបាលកងដឹកជញ្ជូន បានធ្វើ សាក្សីអោយយើង ។ (នេះចំណុចសំខាន់)

ទីនេះទៀតសោត មានភស្តុតាងឆ្លងតំកល់ទុកនៅចេតីយវត្តនេះ ឯខ្មោះយកទៅរក្សាទុកនៅ ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង (ភស្តុតាង ) ។

សាក្សី ៣នាក់ទៀត ជាស្រី ១ រងគ្រោះ ធ្លាប់រងជាប់គុក ហើយត្រូវគេដុតពោលទាំងរស់ ប៉ុន្តែមិន ស្លាប់ ១នាក់ នេះសំខាន់ ដឹងរឿងពិត ។ (ដោយពេលវេលាខ្លី មិនបានសម្ភាសន៍) ។

ដូច្នេះខ្ញុំយល់ថា ទីតាំងនេះសំខាន់ច្បាស់ មិនអាចប្រកែកបានឡើយ មិនមែនស្មានៗទេ គឺមាន សាក្សី ដឹង ឃើញ និងរងគារុណកម្មជាប់គុក ។

យើងស្តាយដោយទៅមិនដល់ទីតាំង គឺដោយសារពេលវេលា ផ្លូវគមនាគមន៍ និង សន្តិសុខនៅ មូលដ្ឋាននេះមិនធានា ។

## ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ១៩៩៨

## II- <u>ស្រុកកំពង់លែង</u>

ក្រុមយើងបានធ្វើដំណើរពីសាលាខេត្តកំពង់ឆ្នាំង តាមផ្លូវជាតិលេខ ៥ ដែនន្លេសាប ឆ្ពោះទៅកាន់ សាលាស្រុកកំពង់លែង ចំងាយផ្លូវទឹក ៦ គីឡូម៉ែត្រ ១ ម៉ោង ៨ព្រឹក ទៅដល់សាលាស្រុក ប្រើពេលអស់ ៤៥នាទី ។

នៅទីនោះយើងបានជួបអភិបាលស្រុកលោក **សឺម អឺ** និងមន្ត្រីស្រុក ១ នាក់ទៀត ។

**<u>ទីតាំងផ្សេងៗ</u>**

ទីតាំងសាលាស្រុកឋិតនៅទិសឦសាន ខេត្តកំពង់ឆ្នាំង ចំងាយ៦គីឡូម៉ែត្រ ។ ជាតំបន់វាលទំនាប ខ្ពង់រាប និងភ្នំច្រើន ។

<u>ព្រំប្រទល់ស្រុក</u> :

- ខាងជើង ស្រុកសន្ទុក ខេត្តកំពង់ធំ
- ខាងត្បូង ស្រុកសន្ទុក រលាប្អៀរ ខេត្តកំពង់ឆ្នាំង

8 ខាងលិច ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង

8 ខាងកើត ស្រុកបារាយណ៍ ខេត្តកំពង់ធំ

- ចំនួនឃុំមាន ៩ ភូមិ ៨៤ ចំណុះស្រុក
- ប្រជាជនសរុប ៣២,៦០៣ នាក់ ស្រី ១៨,២២១ នាក់ ។
- មុខរបរប្រជាជន ភាគច្រើនធ្វើស្រែ ស្រែរាស្យា ស្រែជ្រាំង នេសាទត្រី ចំការខ្នះៗគួបដូរ ។
- ប្រជាជនអាយុ ១៨ ឆ្នាំ ឡើង មានសិទ្ធិបោះឆ្នោត ១៨,៥៨៥ នាក់ ។
- សម័យប៉ុល-ពត តំបន់ ៣១ ភូមិភាគបច្ចឹម ។

ឃុំចំណុះស្រុកសម័យប៉ុល-ពត មាន ១១ឃុំ សព្វថ្ងៃ មានតែ ៩ឃុំទេ ។

**<u>ពតីមានទាក់ទងអំពើប្រល័យពូជសាសន៍</u>**

**<u>គុកសន្តិសុខ កន្លែងសម្ងាប់</u>**

**- នៅភូមិក្លែងពណ៌ ឃុំត្រងិល**

**+ <u>កន្លែងសម្ងាប់</u>** : ក្បែរៗគុក

១- ជួរភ្នំទូកមាស ឆ្ងាយពីសន្តិសុខគុក ៥ គីឡូម៉ែត្រ (សន្តិសុខមិនធានា)

២- ចំណុចភ្នំល, ភ្នំរធៀង, ដីរកប់កូន

៣- ចំណុចតូចជាច្រើនកន្លែងនៅក្បែរទីនោះ

៤- ក្រោយភូមិកំពង់ជាស្រូវចុងបឹង ស្តីតាកែវពោធិពួនភ្នំ ឋិតក្នុងឃុំព្រៃត្រី ។

៥- មុខវត្តពាមឆ្កោត ព្រៃបាណាត ព្រែកអណ្តូង ឋិតក្នុងឃុំពាមឆ្កោត ។

៦- អណ្តូងតាបេង ព្រៃខ្ញាច់ ស្រែតាហុច ត្រពាំងមាលា ឋិតនៅក្នុងឃុំស្វាយរំពារ ។

៧- ស្រែវែង, ដើងភ្នំប្រាសាទ (ឋិតក្នុងភូមិដា) ។

៨- ភ្នំត្រុំ (ឋិតក្នុងឃុំត្រងិល) ។

ក្រោយពីយើងបានដឹងពត៌មានខាងលើហើយ យើងបានចុះទៅទីតាំងឃុំ៣ ដំបូងឃុំឆ្ងាយពីសាលា ស្រុក ២០ គីឡូម៉ែត្រ ទីតាំងសម្ងាប់ឯាលស្រែវែង (គុកសន្តិសុខឃុំពីសម័យប៉ុល-ពត) ។ ទីនេះបច្ចុប្បន្ន សន្តិសុខឋិតក្នុងការភ័យខ្លាច

ប៉ុន្តែយើងទៅដោយតស៊ូពលីកម្ម បួលិស ២នាក់ កងការពារ ១នាក់ ម៉ូតូឌុប ៤ គ្រឿង ។ យើងសួរទាហានយើងបណ្តើរៗ ម៉ោង ១០:០០ ព្រឹក ដល់ទីតាំង ។

<u>នៅម៉ោង ១០:០០ព្រឹក</u>

ជួបមេភូមិឈ្មោះ **កន គឿន** អាយុ ៨៩ឆ្នាំ និងលោកតា **អ៊ុន ខឿន** អាយុ ៦៦ឆ្នាំ ។ ប្រជាជនភូមិជ្រាសាទ ឃុំដាសព្ងៃ សម័យប៉ុល-ពត រស់នៅទីនោះផ្ទាល់តែម្តង ។ មេភូមិជាកងចល័ត សម័យ **ប៉ុល ពត** ។ ក្រោយឆ្នាំ ១៩៧៩ មកស្រុកកំណើតវិញ ។

**<u>អំពីតំបានមេភូមិ សាក្សី</u>**

លោកតា **អ៊ុន ខឿន** សាក្សី គាត់បានប្រាប់យើងដូចតទៅ :

ទីតាំងសម្គាល់នៅវាលស្រែវែង សម័យសីហនុដាំសណ្តែក សម័យ **ប៉ុល ពត** ព្រៃ ក្រោយឆ្នាំ ១៩៧៩ ដាំសណ្តែកក្បែរនេះ មានវាលស្រែវែងមែន ។ ទីនេះជាទីតាំងសម្គាល់ពិតប្រាកដមែន ។ គាត់បាន ដឹងថា ឃើញគេជីករកមាសនៅឆ្នាំ ១៩៨៣-១៩៨៤ និងពិសេសនៅឆ្នាំ ១៩៨០ បានទៅឃើញរណ្តៅ នៅទីនោះ ជាក់ស្តែង ។

- អំពីរណ្តៅ ធំៗមាន ៣ ត្រពាំងទឹក ១
- ទំហំរណ្តៅ មាត់លើ ៣ម៉ែត្រ បណ្តោយ ៦ម៉ែត្រ ជិតៗ ១,៥០ម៉ែត្រ ។
- ចំនួនអ្នកស្គាល់នៅទីនោះ (សាក្សីមិនដឹង បើមានឱកាសស្រាវជ្រាវបន្តទីនោះទៀត) ឆ្នាំ ១៩៧៥-៧៦ និង ១៩៧៧ តៗ រហូតឆ្នាំ ១៩៧៩ ។
- ប្រភេទជនរងគ្រោះ អ្នកជំលៀសចេញពីទីក្រុងផ្សេងៗ គេបញ្ជូនមកទីនេះ ១៩៧៧ គេប្រើ ជ្រាស់អោយលើកទំនប់ អ្នកខុសឆ្គង មានជាប់និទ្ទាការផ្សេងៗសម្គាល់ទាំងគ្រួសារ ចាប់ខ្ទី -ម៉ែ យកទាំងកូន ។ កំទេចវណ្ណៈអ្នកមាន គេប្រមូលអ្នកខ្លះមកពីឃុំដា សហករណ៍ភូមិ និងមានពីបណ្តាឃុំនានាខ្លះដែរ ក្នុងស្រុកកំពង់លែង ។

- ប្រជាជនចាស់ក៏សម្លាប់ដូចគ្នា អោយតែខុស ។
- នៅជើងភ្នំប្រាសាទ មានផ្នូរខ្មោចឪហ៊ាន **ប៉ុល ពត** កម្មាភិបាលយោធាពួកវាវាប់រយពាន់ ផ្នូរដែរ ។
- តាមពត៌មាន ពីលោកតា **ខ្សឿន** គាត់នៅទីនោះ អ្នកមកទីនេះកម្រួចរស់ណាស់ ស្លាប់ទាំង អស់ ។

**<u>សញ្ញាសំគាល់ទីតាំងសម្លាប់</u>**

◊ វាលស្រែវែងនោះនៅចន្លោះភ្នំថ្មរៀង ភ្នំប្រាសាទ ភ្នំកង្កែប ។

◊ ពាក្យបូរាណ មានដើមស្វាយស ចំការសណ្តែក មានត្រពាំង ១ ចំកណ្តាល ។

ឋិតក្នុងភូមិប្រាសាទ ឃុំដា ស្រុកកំពង់លែង ។ ខាងឆ្វេងដៃ ចុះពីថ្នល់ ៧០០ ម៉ែត្រ ។

+ <u>ម៉ោង ១១:៣០ នាទី</u>

មកដល់សាលាឃុំស្វាយរំពារ ស្រុកកំពង់លែង

× ទីតាំងសន្តិសុខគុកឃុំ ឈ្មោះ **អូតាប៊ុន**

× កន្លែងសម្លាប់ព្រៃខ្ទាប់ ១ កន្លែង

× អណ្តូងតាបេង ១ កន្លែង

**<u>អំពីពត៌មានទាក់ទងទីតាំងនោះ</u>**

លោក **ស្រី សំរឿន** សព្វថ្ងៃនៅភូមិលា ឃុំស្វាយរំពារ គាត់បានប្រាប់យើងថា នៅព្រៃខ្ទាប់ និងអណ្តូងតាបេង ជាទីតាំងសម្លាប់ដ៏ធំមួយ ចំងាយពីសន្តិសុខគុកនេះ មានចំនួន ១ គីឡូម៉ែត្រ ។

ក្រុមយើងបានទៅពិនិត្យទីតាំងនោះដោយមានលោក **ម៉ី សាឡន** អាយុ ២៧ឆ្នាំ ដើមកំណើត រស់នៅភូមិលា ឃុំស្វាយរំពារ សព្វថ្ងៃ ។ សម័យ **ប៉ុល ពត** ជាកុមារ អាយុ ១០ ទៅ ១១ឆ្នាំ គាត់បាន ឃើញដឹងតាមរយៈចាស់ៗនិយាយប្រាប់គាត់ផង និងបានមកឃើញកន្លែងសម្លាប់នោះក្រោយឆ្នាំ ១៩៧៩ ។

មន្ទីរតាបេង : **តាបេង** ជនកុម្មុយនិស្ត ជាខ្មែរក្រហមម្នាក់ គាត់ជាមេគេកសាងមូលដ្ឋានបដិវត្ត នៅទីនេះជាកន្លែងមូលដ្ឋានតស៊ូមុនឆ្នាំ ១៩៧០ ។

ព្រៃខ្ទាច់: ព្រៃនេះមានទំហំក្បាល១គីឡូម៉ែត្រ បណ្តាយវែងរាប់គីឡូម៉ែត្រ មិនអាចប៉ាន់ស្មានបាន។ គាត់ប្រាប់យើងថា គុកសន្តិសុខឃុំស្វាយរំពារនេះ កសាងឆ្នាំ ១៩៧៥ រហូត ១៩៧៩ ហើយកន្លែង សម្លាប់នោះកសាងមុនឆ្នាំ ១៩៧០ និងក្រោយឆ្នាំ ១៩៧០-៧៥-៧៦ រហូត ១៩៧៩ សម្លាប់រហូត ។

ប្រភេទជនរងគ្រោះ ឆ្នាំ ១៩៧៥-៧៦ ប្រជាជនមន្ត្រីរដ្ឋការស៊ីវិល គ្រូបង្រៀន ទាហាន។ល។ អ្នកដំលៀសចេញពីទីក្រុងនានាឆ្នាំ ១៩៧៦-៧៩ ចំរាញ់និន្នាការ រួចយកសម្លាប់ទីនោះ ។ ទីនោះសម្លាប់ ទាំងក្មេង ទាំងចាស់ ប្រុស ស្រី ចាប់ ខ្ទី-ម៉ែ យកកូនសម្លាប់ទាំងគ្រួសារ។ ទាំងប្រជាជនថ្មី និងប្រជាជន ចាស់ អោយតែខុសសម្លាប់ទាំងអស់ ។ នៅឆ្នាំ១៩៧៣-៧៤ សម្លាប់ពួកទាហានសម័យ **លន់ ណុល** បែកបន្ទាយ ពួកគេចាប់បាន ។ មួយចំនួនធំយកចេញពីគុកសន្តិសុខឃុំស្វាយរំពារ ឈ្មោះថា **អូតាប៊ុន** ។ និយាយរួមយក ពីគ្រប់សហករណ៍តាមភូមិ ក្នុងឃុំស្វាយរំពារតែម្តង និងអាចមានពីទីកន្លែងផ្សេងៗ ។ (១៥ ទៅ ២០ រណ្តៅ )

**<u>អំពីរណ្តៅសម្លាប់សាកសពម្នាក់</u>** ធំៗមាន ២ :

ទី១ : <u>នៅអណ្តូងតាបេង (ឬ ក្បាលខ្ទោច)</u> សម្លាប់ពេញ មាត់លើ ៣ ម៉ែត្រ ជំរៅ ៥ម៉ែត្រ សម្លាប់ដាក់ពេញ។ ។

ទី២ : <u>ព្រៃខ្ទាច់</u> ឆ្ងាយពីទីនេះ ៥០០ ម៉ែត្រ ក្នុងព្រៃខ្ទាច់នេះជាកន្លែងសម្លាប់ពេញក្នុងព្រៃ ៦ ក្បែរៗអណ្តូងក៏មានរណ្តៅដែរ ប៉ុន្តែលប់អស់ ។

យើងអោយសាកូវីចង្អុល រួចថតទុកចំណាំនូវរណ្តៅនិមួយៗ គឺអណ្តូងតាបេង ។

+ <u>ម៉ោង ១២:១០ នាទី</u>

យើង និង សាកូរី រួមទាំងកងការពារ ៣នាក់, សហការីទៅចុច Computer ធ្វើដែនទីតាំង សម្រាប់ ទាំង២ នេះ ។ សាកូរី **ម៉ី សាច្បុន** បង្ហាញឆ្នើងជនរងគ្រោះ ។ មានក្រណាត់ខោអាវនៅ សេសសល់ ។

**<u>អំពីទំហំចំនួនរណ្តៅនីមួយៗ</u>**

៣ ម៉ែត្រ បួនជ្រុង ៦ ម៉ែត្រទទឹង ៦ ១២បណ្តោយ ជិត ១,៥០ម៉ែត្រ ទៅ ២ម៉ែត្រ ។ យើង ដើរទៅក្នុងព្រៃនេះតាមផ្លូវនេះ ផ្លូវឡានមានសុទ្ធតែដីខ្សាច់ ខ្សាច់ពណ៌ស សសុទ្ធ ព្រៃខ្សាច់ទាំងមូល រណ្តៅពេញ ប៉ុន្តែថ្ងៃត្រង់ម៉ោង ១២:១០ នាទី កំពុងតែក្តៅ យើងមិនបានរាប់ចំនួនរណ្តៅអស់ឡើយ ។ យើងស្មាន ដោយសាកូរីប្រាប់យើងថា ១ ណ្តៅ អាចវៃសម្រាប់ ៥០ នាក់ ១០០នាក់ ១៥០ នាក់ តាមតូច ធំ ។

សាកូរីប៉ាន់ស្មានអ្នកស្លាប់ប្រហែល ៦,០០០ នាក់ និងអាចជាង ៦,០០០ នាក់ដង ។

**<u>+ ម៉ោង ១៣:០០ គឺម៉ោង ១:០០ រសៀល</u>**

**<u>ទីតាំងសន្តិសុខគុក កន្លែងសម្លាប់</u>**

ឈ្មោះភូមិបាន ជាត់ ភូមិក្លែងពណ៌ ឃុំត្រងិល ស្រុកកំពង់លែង

- ទីតាំងនេះចំងាយពីសាលាស្រុក ១ គីឡូម៉ែត្រ ទៅ ១,៥០ គីឡូម៉ែត្រ ។
- នៅទីនោះយើងបានជួបលោកយាយ **យំ** និងលោកពូ **កេត ស្រ្សៀន** ។

  សព្វថ្ងៃលោក យាយ **យំ** និងលោកពូនេះ នៅចំទីតាំងគុកសន្តិសុខនេះតែម្តង គាត់ប្រាប់យើងថា ខាងស្តាំ ដៃទី១ គុក មានផ្ទះក្បឿង ២ (ពីរ) ដាក់ជនរងគ្រោះពេញៗទាំងអស់ ឯផ្ទះទី២ ខាងឆ្វេងដៃ ផ្ទះក្បឿង ២ ត្រឿង ។ គេដាក់ខ្នោះជើង ដោតដែកជាជួរៗពេញ លោកយាយ **យំ** នេះ សម័យ **ប៉ុល ពត** គាត់ មកជីកកួច ឃើញជាក់ស្តែង ។

ចំពោះកន្លែងសម្លាប់ : នៅឆ្ងាយពីគុក ១០ ម៉ែត្រ ទៅ ២០ម៉ែត្រ

១- វាលច្រាប់ ខាងត្បូងគុក

២- ត្រយោគ ខាងលិចគុក

៣- នៅពោធិជ្រៃ

៤- ខាងជើងគុក

ដូច្នេះនៅក្បែរៗនេះសុទ្ធតែព្រៃ ហើយឆ្នាំ ១៩៨១ គាត់មកជីកវើសឆ្នឹង បានឃើញរណ្តៅជាច្រើន នៅក្បែរៗនោះ ។ គាត់វើសឆ្នឹងគរនៅគល់ត្នោត ឆ្នឹងគេគាស់រកមាស ១៩៨៣-៨៤ ឆ្នឹងគេយកទៅទុកសា លារៀន និងវត្ត (ជាត់បង់អស់ហើយសព្វថ្ងៃ) ។

ចំនួនរណ្តៅទីនេះច្រើនណាស់ យើងជាន់ស្មានប្រហែល.....? រណ្តៅ.....? ។

ចំនួនអ្នកស្លាប់.....? នាក់ ទៅ .....? នាក់ ។

សាកូវី ពូ **ស្រ្បែន** យាយ **យ៉ំ** បានប្រាប់អ្នកធ្លាប់ជាប់គុកនៅគុកសន្តិសុខស្រុកកំពង់លែង ស្រុក១២ សម័យប៉ុល-ពត នេះឈ្មោះ **ប្បឿន** នៅឃុំតាងិលសព្វថ្ងៃ ។ **ហាស អេងលីន** គ្រូបង្រៀន សព្វថ្ងៃនៅអប់រំស្រុក ។

<u>សេចក្តីបញ្ជាក់</u> : នៅគុកនេះ គុកធំរបស់ស្រុក ពត៌មានថា មាននាំទៅសម្លាប់នៅជួរភ្នំទួកមាស ភ្នំត្រងិល ។ សម្លាប់ជាច្រើនដូចជា :

| | |
|---|---|
| ១- ជួរភ្នំទួកមាស | ព្រៃបាណាក់ ព្រៃអញ្ចាង |
| ២- ចំណុចគុល | មុខវត្តពាមឆ្កោត |
| ៣- ភ្នំត្រងៀង | ក្រោយភូមិកំពង់ជាស្រូវ |
| ៤- ដីរកប់កូន | ស្តឹតាកែវ ពោធិពួនភ្នំ |

+ <u>ទីតាំងសម្លាប់នេះយើងទៅមិនបាន</u> ៥ គីឡូម៉ែត្រ ស្ថានភាពភ្លាំងចូលថ្ងៃ ២២-៦-៩៨ ចូលភូមិ ស្រែត្បិច ឃុំច្រណូក ។ ពួកខ្មែរក្រហមសុទ្ធសាធ ចៅហ្វាយស្រុកមិនអនុញ្ញាតឲ្យយើងទៅទីនោះឡើយ ។

## <u>សេចក្តីសន្និដ្ឋានផ្ទាល់</u>

នៅស្រុកកំពង់លែង បើតាមពត៌មាន មានច្រើនណាស់ទីតាំងសម្រាប់ ប៉ុន្តែយើងទៅមិនដល់ បើ ទៅបានចូលតាមឃុំច្រណូកទើបចូលដល់ អាចមាន ប៉ុន្តែយើងទៅមិនបាន ដោយសារពួកខ្មែរក្រហមពី១៥ នាក់ ទៅ ២០នាក់ ចូលឃុំនេះថ្មីៗ ថ្ងៃ ២២-៦-៩៨ ។ ថ្ងៃទី ២៣-៦-៩៨ យើងចុះស្រុកនេះ ។ បើគិត ចំងាយជាង ២០គីឡូម៉ែត្រ, ២៨ គីឡូម៉ែត្រ ។ ដោយស្ថានភាព ខ្លាំង ពេលវេលា ដូច្នេះយើងធ្វើការតក់ ក្រហល់ មិនអាចសែងរកអ្នកជាប់គុកធ្វើសាក្សីបាន ។

ម្យ៉ាងទៀត ផ្លូវពីស្រុកទៅខេត្ត យើងព្រួយបារម្ភខ្លាំងពេលរសៀលម៉ោង ១៥:០០,១៨:០០ ខ្លាច ភ្លៀង តាមដងទន្លេព្យុះ ។ យើងមិនអាចនៅធ្វើការដល់ម៉ោង ១៧:៣០ បាន ។

ដូច្នេះក្នុងស្រុកកំពង់លែងនោះ បើសិនជាថ្ងៃ ខែ ឆ្នាំ ខាងមុខ មានស្ថេរភាព សន្តិសុខធានា គួរតែ ចុះស្រាវជ្រាវបន្តទៀត ។

ចប់ស្រុកកំពង់លែង ម៉ោង ១៥:០០ ។

## ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៨

## III- ស្រុករលាប្អៀរ

នៅម៉ោង៧:៣០ យើងបានមកជួបលោកចៅហ្វាយស្រុករលាប្អៀរ ឈ្មោះ **អ៊ាន ឈា** យើង បានចុះសុំទំនាក់ទំនងជាបពីគោលបំណង និងសំណូមពររបស់ក្រុមស្រាវជ្រាវយើង ។ គាត់បានប្រាប់ ឈ្មោះឃុំ ដែលមានទីតាំងប្រល័យពូជសាសន៍ ។

*** អំពីពត៌មានផ្សេងៗ**

ទីតាំងសាលាស្រុកឋិតនៅតាមបណ្តោយផ្លូវជាតិលេខ ៥ នៅខាងត្បូង សាលាខេត្តកំពង់ឆ្នាំង ចំងាយ ៣ គីឡូម៉ែត្រ ។ សម័យ **ប៉ុល ពត** តំបន់ ៣១ ភូមិភាគបច្ចឹម ។

ស្រុកនេះជាតំបន់ភាលរាប ព្រៃភ្នំ ព្រៃរនាម ព្រៃស្ដុប ជាប់ភាលដងទន្លេ ។

- មាន ១៣ឃុំ និងមាន ១៣១ភូមិ មាន ១៦,៧៧៥ គ្រួសារ ។
- មានប្រជាជនរួម ៧៩,០៥០ នាក់ ។
- ប្រជាជន ១៨ឆ្នាំ ឡើង មានសិទ្ធិបោះឆ្នោត ៤០,៦៧៥ នាក់ ។
- មុខរបរប្រជាជន ធ្វើស្រែ ឡើងភ្នោត សិប្បកម្ម កូមឆ្នាំង ចង្រ្កាន ល្អើកញ្ជើរ ។ល។

ព្រំប្រទល់ស្រុក

- ខាងជើង បរិបូរណ៍
- ខាងត្បូង កំពង់ត្រឡាច
- ខាងលិច ទឹកផុស
- ខាងកើត ជលគីរី

## * <u>អំពីទីតាំងប្រឈ័យខ្លួជសាសនំ</u>

លោកចៅហ្វាយស្រុកបានប្រាប់យើងថា ទីតាំងសម្ភាប់សន្តិសុខគុក មានដូចតទៅ :

១- ចុងប្រាសាទ ឋិតក្នុងឃុំអណ្តូងស្នាយ
<u>កន្លែងសម្ភាប់</u>

២- <u>ជាលខ្លាចស់រ ឬព្រៃខ្លាចស់រ ទួលខ្លាចស់រ</u> ឋិតក្នុងឃុំអណ្តូងស្នាយ

៣- <u>សន្តិសុខគុក កន្លែងសម្ភាប់</u> ចុងក្រោយរបស់ស្រុក ១០ សម័យ **ប៉ុល ពត** រលាប្អៀរ សព្វថ្ងៃ ។

៤- ចំបក់, អូឬស្សី, កងមាស, ព្រៃកោះ, ជាលទឹកដោះ, ទួលអាំ, ចុងតាណាង, អណ្តូងផ្តៅ, ខ្មោចយួន, ដើមសំលាង, ចំបក់ប្រហោង ។ ឋិតនៅក្នុងឃុំគោកបន្ទាយ ឃុំបន្ទាយព្រាល ឃុំទឹកហូរ, អូរលៀច ។

ក្រោយពីទទួលបានពត៌មានពីចៅហ្វាយស្រុក ឯកសាររបស់មន្ទីរវប្បធម៌ខេត្តរួច គាត់បានប្រាប់ឲ្យ យើងទៅជួបលោកមេឃុំ មេភូមិ

ដែលគេកំពុងតែរៀបចំប្រជុំបើកកម្មវិធីឃោសនាគោលការណ៍គណៈ បក្ស
លើកដំបូងនៅសាលារៀន ។

យើងទៅដល់ទីនោះជួបអភិបាលរងស្រុក រួចជំរាបគាត់
យកចំណារអភិបាលស្រុកបង្ហាញគាត់ មេឃុំ អណ្តូងស្នាយបានចាត់មេភូមិ ១នាក់
អនុប្រធានភូមិ ២នាក់ ជិះរថយន្តជាមួយយើង នាំទៅបង្ហាញ ទីតាំងប្រល័យពូជសាសន៍ធំៗ
៣កន្លែងគឺ :

១- ចុងជ្រាសាទ

២- ព្រៃខ្សាច់សរ ឬទួលខ្សាច់សរ អាចថារាលខ្សាច់សរ (ខ្សាច់សរមែន) ។

៣- ចុងជ្រោយ

- ឈ្មោះអ្នកនាំផ្លូវមាន :

១- **ចាន់ ចំ** អាយុ ៥៨ ឆ្នាំ មេភូមិអណ្តូងស្នាយ

២- **សឹម សំអ៊ិន** អាយុ ៣៩ ឆ្នាំអនុប្រធានភូមិ

៣- **ម៉ក់ សារី** អាយុ ៨៥ ឆ្នាំអនុប្រធានភូមិជ្រាំហ៊ី

## ១- <u>ទីតាំងសម្លាប់ចុងជ្រាសាទ</u>

យើងត្រូវធ្វើដំណើរតាមផ្លូវជាតិលេខ ៥ បានចំនួន ៣ គីឡូម៉ែត្រ បត់ឆ្វេងដៃ
ចូលជ្រៅទៅដល់ ទីតាំងសម្លាប់ នៅចុងជ្រាសាទ ចំងាយពីផ្លូវជាតិ ៨ គីឡូម៉ែត្រ
ពីសាលាស្រុក ១១ គីឡូម៉ែត្រ ។ នៅទីនោះ ឈ្មោះ **អៀម ចាន់** អាយុ ៣៧ ឆ្នាំ
ជាប្រជាជននៅភូមិជ្រាំហ៊ី ចំងាយ ៣ គីឡូម៉ែត្រ ពីទីតាំងសម្លាប់ ចុងជ្រាសាទនេះ ។
ទីនេះឋិតក្នុងភូមិជ្រាំហ៊ី ឃុំអណ្តូងស្នាយ ។

+ <u>ពត៌មានលំអិតពីសាក្សីចាំង ៨នាក់ នៅទីតាំងសម្លាប់ចុងជ្រាសាទ</u>

នៅទីតាំង យើងពិនិត្យទីតាំងសញ្ញាសំគាល់ទីតាំង ចំនួនរណ្តៅសាកសព ស្នាមរណ្តៅ កស្តុតាង ជាក់ស្តែង គឺរណ្តៅមិនទាន់រលប់អស់នៅឡើយទេ យើងថតរណ្តៅ ហើយអោយសាក្សីចង្អុលបង្ហាញ ។

+ <u>ទីតាំងសំគាល់</u> ព្រៃប្រស្សីព្រៃ ដើមស្វាយ ដើមត្នោត ជាភូមិកំណើតជីដូនជីតាលោក **សឺម សំអ៊ិន** ស្រាប់ ប៉ុន្តែបច្ចុប្បន្ន គ្មានផ្ទះ ឬប្រជាជនរស់នៅទេ ។ ចំងាយពីភ្នំព្រះ (ភ្នំឥន្ទ្រប៉ះបូរី) ១ គីឡូម៉ែត្រ ។

+ <u>ចំនួនរណ្តៅរួមសំរាប់កប់សាកសព និងអ្នកស្លាប់</u>

ពត៌មានពីសាក្សី និងបានឃើញដូល់ភ្នែកដងនោះ គឺប៉ាន់ស្មានជាក់ស្តែង ប្រហែល ១៥០ ទៅ ២០០ រណ្តៅ បើគិតពីអ្នកស្លាប់មាន ពី ៣នាក់ ទៅ ៤នាក់ និង ៥នាក់ ក្នុង ១រណ្តៅ ដូច្នេះអាចប៉ាន់ពី ៤៥០នាក់ ទៅ ៦៤០នាក់, ៧៥០នាក់ និងពី ៦០០ នាក់, ៨០០ នាក់ ទៅ១,០០០នាក់ សាក្សីគាត់អាច ថាលើសពី ១,០០០ នាក់ អាច ១,៣០០នាក់ ។

- ប្រភេទជនរងគ្រោះស្លាប់នៅចុងក្រោយនេះ តាមសម្តីសាក្សីរាយការណ៍ នៅចុងឆ្នាំ ១៩៧៥-៧៦ ប្រជាជនដឹកតាមការណែនាំ កប៉ាល់ ពីខេត្តកោះកុង យកមកដាក់នៅសហករណ៍ បញ្ជូនតាមភូមិ ឃុំ ឆ្នាំ ១៩៧៦-៧៧ ចាប់ផ្តើមចំរាញ់ប្រវត្តិរូបនិន្នាការ មន្ត្រីរដ្ឋការ ស៊ីវិល ទាហាន ប៉ូលិស គ្រូ សាស្ត្រាចារ្យ សិស្ស និស្សិត បញ្ញវន្ត បើនរណាធ្លឹអ៊ី អោយធ្លឹដូចដើមវិញ អង្គការ មិនយកទោស មិនបោះបង់ចោល បើខ្ចីម៉ែ ឆ្លើយថា សត្តិ២ ឬ សាស្ត្រាចារ្យ ប៉េអឹម បូលីស យកទាំងគ្រួសារ។ កូន ប្រពន្ធ (ដឹកស្មៅដឹក ទាំងឫស)

តាមផ្លូវទឹក ដឹកពីកោះកុង ឡើងកំពង់ចំលងព្រែកសាឡា ។ ដឹកតាមដៃទន្លេសាប។ ខ្មែរក្រហម មានវិធីដូចប្រជាជនពីបូពាំ យកទៅបច្ចឹម ពីបច្ចឹម យកមកបូពាំវិញ ។

<u>ឆ្នាំ ១៩៧៧-៧៨ គេចំរាញ់</u> : វណ្ណៈអភិជន អ្នកមាន។ អ្នកមាននិន្នាការ បងប្អូនសាច់ញាតិធ្លឹ ទាហាន ប៉ូលីស មន្ត្រីនៅទីក្រុង កំទេចចោលគ្មានសល់កូនតូចតាចទេ បើសិនដឹងថាជាប់និន្នាការ ។

ទំហំដី សម្រាប់ ១ហិកតា បួនជ្រុង ពេញទាំងអស់ សាក្សីបានមកឃើញពេលគាត់ចូលស្រុកឆ្នាំ ១៩៧៩ គាត់រកមាស ១៩៨០-៨២-៨៣ ខ្មោចនៅហើមស្គុល ក្លិនស្អុយ ទឹកឈាម កខ្វក ខោអាវ មិនទាន់រលួយនៅឡើយ ច្បូតយកសាច់ចេញ ។

អដ្ឋិធាតុ ឆ្អឹងនៅទីនោះគ្មានបានរើសទុកទេ ដូច្នេះទីតាំងសម្រាប់នេះវាប្រមូលពីសហការណ៍តាមឃុំ និងប្រជាជនដែលៀសពីកោះកុង និងពីទីក្រុងនានា ទាំងប្រជាជនថ្មី ចាស់ អោយតែខុស ។

សាក្សីបានប្រាប់យើងថា : មេសន្តិសុខខ្មែរក្រហមនៅចុងប្រាសាទនេះឈ្មោះ **កុយ តេង, អាគុជ, អាស្ងួន,** កូនតា **ជៀត** នៅកំពង់សាឡា ។ ឯវារស់នៅឃុំព្រៃកន្ធោ ស្រុកជលគីរី ឃុំ កំពង់អូស សព្វថ្ងៃយោធាឃុំ (នៅរស់) ។

## ២- ទីតាំងសន្តិសុខគុក សម្លាប់

### * វត្តត្រពាំងទឹកត្រជាក់

ទីនេះជាមន្ទីរអប់រំសន្តិសុខគុក ឃុំអណ្តូងស្នាយ ភូមិអូតាសេក ទីតាំងនេះនៅក្នុងវត្តត្រពាំងទឹក ត្រជាក់តែម្តង ។ យើងថតមន្ទីរសន្តិសុខរណ្តៅសាកសព ។ (ម៉ោង ១០:១០ មកដល់ទីនោះ) ។ មកទី នេះធ្លើដំណើរកាត់ភាលប្រាប ព្រៃបំពង់ត្រាច (ព្រៃឈើត្រាច) ឆ្លងកាត់ភូមិបំពង់ដូង ដល់ភូមិតាសេក ដល់វត្តចំការ ៦ គីឡូម៉ែត្រ ។ រថយន្តបើកតាមដងវែរនេះ ។

+ **ម៉ោង ១១:៣០ នាទី**

យើងទៅពិនិត្យរណ្តៅសាកសព ចុចComputer គួរដែនទី និងថតចង្អុលបង្ហាញរណ្តៅ ទំហំរណ្តៅ មាត់លើ ៣ម៉ែត្រ បួនជ្រុង ៤ម៉ែត្រ បួនជ្រុង រណ្តៅធំៗ មាន ៣ ប៉ាន់ស្មានវាយសម្រាប់ ១ រណ្តៅ ១០នាក់ ទៅ ៧០ នាក់ ឬ ១០០ នាក់ ។ សរុបអ្នកស្លាប់នៅទីនោះ ១៥០ នាក់, ១៧០ នាក់ ទៅ ២៣០ នាក់ ។

ប្រភេទជនរងគ្រោះទីនេះគឺ :

ជាកម្មាភិបាល **ប៉ុល ពត** ប្រជាជនខុសសីលធម៌ផ្សេងៗ យកពីបណ្តាសហករណ៍ភូមិនានា ឋិត ក្នុងឃុំអណ្តូងស្នាយ ។ និងអនុប្រធានភូមិ ២នាក់ទៀត ជាន់ដីង ។ គាត់រួមដំណើរជាមួយក្រុមស្រាវជ្រាវ ។

+ **ម៉ោង ១១:២០ នាទី**

## ៣- ទីតាំងសម្លាប់ (គ្មានគុក)

ព្រៃខ្សាច់សរ អាចហៅ ទួលខ្សាច់សរ ឬវាលខ្សាច់សរ

ទីតាំងសំគាល់

១- រោងប្រក់ក្បឿង ថតរូប នៅលើទួលធំ កសាងដោយប្រជាជនឃុំអណ្តូងស្នាយ

២- អណ្តូងទឹក ១ គុម្ពឫស្សីព្រៃ ១ (ថតរូប) ចំងាយពីភ្នំតានន់ ១គីឡូម៉ែត្រ ទៅ១,៥គីឡូម៉ែត្រ

បញ្ជាក់ : ទីតាំងនេះជាដីទួលខ្ពស់មានព្រៃរោះៗ ព្រៃស្រោង ហើយខ្សាច់សរមែនពិត ។ សព្វថ្ងៃប្រជាជន មកពីជុំវិញ រាស់ដីចែកគ្នា ធ្វើចំការដំណាំ ។

ទីតាំងនេះប្រជាជនគេរួបរួមគ្នាធ្វើបុណ្យរំលឹកវិញ្ញាណក្ខន្ធ អ្នកស្លាប់រៀងរាល់ឆ្នាំ បុណ្យសុំសេចក្តី សុខ ។

នៅទីនេះយើងបានអោយសាកសួរ ៤ នាក់ នាំទៅបង្ហាញរណ្តៅសម្លាប់ ។ ដីព្រៃខ្សាច់សរ មានទំហំ ២ គីឡូម៉ែត្រ បួនជ្រុង ។

### * អំពីរណ្តៅសាកសព

រណ្តៅពាសពេញទាំងអស់ ប៉ាន់ស្មានរណ្តៅធំៗ ពី ៣០០ ទៅ ៥០០ តូចៗរាប់ពាន់រណ្តៅ ។ ដែដី ២គីឡូម៉ែត្រ ចាប់ពីភ្នំតានន់ មកទួលខ្សាច់ ១,៥០គីឡូម៉ែត្រ ទៅចំការដូង ២គីឡូម៉ែត្រ ។ ចំការដូង ចំងាយពីព្រៃខ្សាច់ ១,៥០គីឡូម៉ែត្រ ទៅ ២គីឡូម៉ែត្រ ទីនោះមានរណ្តៅគល់ដូងកប់ដើមដូងពីលើពេញ ចំការតែម្តង ចំការ ១ហិកតា

ទៅ ២ហិកតា .....? (យើងទៅមិនដល់គ្មានផ្លូវ) អាចចូលផ្លូវផ្សេងបាន ។

<u>ចំនួនអ្នកស្លាប់សរុប</u> : ៥០,០០០ នាក់ ទៅ ១០០,០០០ នាក់ មួយសែននាក់ អាច ១៥០,០០០ នាក់ តាមការប៉ាន់ស្មានសាក្សី ៤ នាក់ ។

សាក្សីដាំលាំនៅលើចំការ ឈ្មោះ **ផាន់ ថ័រ** អាយុ ៥៧ ឆ្នាំ នៅភូមិអណ្តូងស្នាយ ឃុំអណ្តូងស្នាយ ។ គាត់បានមកធ្វើចំការនៅទួលខ្សាច់សរ ព្រៃខ្សាច់សរនោះ ៣ឆ្នាំ ហើយ គាត់បញ្ជាក់ច្រាប់យើងថា រណ្តៅឃើញ ដាំលាំ ១៨០ រណ្តៅ ក្បែរៗទួលនោះ ឯឆ្ងាយពីទីនេះរាប់មិនអស់ទេ ប៉ាន់ស្មាន ៥០០ រណ្តៅ ឬទៅ ១,០០០ ។

<u>ប្រភេទជនរងគ្រោះ</u> ស្ថាប់ទីនោះ ពួកឃាតករ ចងទាំងខ្សែរៗបណ្តើរយកពី :

- គុកធំ អូឫស្សី ភូមិបច្ចឹម ឃុំអណ្តូងស្នាយ
- យកពីគុកតាប៉ក់ ភូមិត្បែង
- យកពីគ្រប់សហករណ៍ក្នុងឃុំស្នាយ បណ្តាឃុំនានាទូទាំងស្រុក (១៨) (ស្រុករលាប្អៀរ) សព្វថ្ងៃ
- យកពីបណ្តាស្រុកនានា ពីខេត្តកំពង់ឆ្នាំង

<u>បញ្ជាក់</u> : នេះអាចសន្និដ្ឋានថា (ជាគុកតំបន់ ៨១)

មេពេជ្ឈឃាតឈ្មោះ **ង៉ា កើត,** អា **ស៊ុក** សម័យ **ប៉ុល ពត** នៅរស់នៅខោកខ្ពស់ ស្រុកបរិបូរណ៍ ។ នៅទីតាំងសម្ថាប់នេះគ្មានប្រជាជនរស់នៅក្បែរៗទេ ក្នុងសម័យ **ប៉ុល ពត** ដូច្នេះពិបាករក សាក្សីដឹងពិត អ្នកស្លាប់ចំនួនប៉ុន្មានពិតៗ ? ។ សាក្សី និងយើងប៉ាន់ស្មាន ១០ម៉ឺននាក់ ដោយសារពត៌មានថារណ្តៅច្រើន ទំហំព្រៃសម្ថាប់ ២ ហិកតា បួនជ្រុងពេញ ។

បើយើងរកឃើញមេសន្តិសុខ មេឃាតករនៅទីនោះ ឬក៏បានអ្នកមកស្លាប់គេនាំមក សម្ថាប់ ហើយរត់រួចពីស្លាប់ អាចដឹងការពិតបាន ។

ប៉ុន្តែបើពិនិត្យរណ្តៅធំៗវែង ជ្រៅៗ ជិត២០ឆ្នាំ រលាប់មិនទាន់អស់នោះ អាចស្មានថា សម្ថាប់ ទីនេះច្រើនមែន ដូច្នេះស្វែងរកសាក្សីបន្ថែម បើមានកម្មវិធីបន្ត ។

+ **<u>ម៉ោង ១២:៣០ នាទី</u>**

ពិសារបាយ

+ **<u>ម៉ោង ១៣:០០</u>**

មកដល់ផ្ទះលោកមេឃុំ **ង៉ា អ៊ឹម** អាយុ ៥៦ ឆ្នាំ គាត់ជាមេឃុំ ឃុំគោកបន្ទាយ ។

សំណូមពរ : រួម ដំណើរជាមួយក្រុមស្រាវជ្រាវ ។

## ៤- <u>ទីតាំងគុកសន្តិសុខ កន្លែងសម្ងាប់</u>

<u>ឈ្មោះ **ចុងជ្រោយ**</u>

ឋិតក្នុងភូមិឈើគ្រាច ឃុំគោកបន្ទាយ ។ ទីនេះឋិតនៅខាងកើតវត្តឈើគ្រាច ៣,០០០ ម៉ែត្រ ។ ពីសាលាឃុំ ៥ គីឡូម៉ែត្រ ។ ពីសាលាស្រុក ១០គីឡូម៉ែត្រ ។ នៅខាងកើតសាលាស្រុកឈៀងខាងត្បូង ។

<u>សេចក្តីបញ្ជាក់</u> : ទីតាំងសន្តិសុខគុក នោះតាមសាក្សីអោយដឹងថា ជាសន្តិសុខគុករបស់ស្រុក ១៨ បច្ចុប្បន្ន ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។

- <u>ទីតាំងសម្ងាប់</u> រណ្តៅកប់សាកសពឆ្ងាយពីគុក ១០០ម៉ែត្រ ទៅ ២០០ម៉ែត្រ ។
- ពត៌មានលំអិតស្រង់ពីសាក្សី ២នាក់គឺ

  ១- **រឿន ថា** អាយុ ៣៨ ឆ្នាំ សព្វថ្ងៃនៅភូមិឈើគ្រាច ឃុំគោកបន្ទាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ សម័យ **ប៉ុល ពត** នៅភូមិនេះ ក្បែរគុកសន្តិសុខ ជាកុមារ កងកុមារ នៅរៀន ។

  ២- លោកមីង **រស់ សុខុន** អាយុ ៣៥ ឆ្នាំ សព្វថ្ងៃនៅភូមិឈើគ្រាច ឃុំគោកបន្ទាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ សម័យ **ប៉ុល ពត** ជាកងចល័តតំបន់ មកធ្វើ ការនៅភូមិឈើគ្រាច ឃុំគោកបន្ទាយនោះ ។

សាក្សី ទី១ និង ទី២ នេះសំខាន់ណាស់ ដោយគាត់បានឃើញគេបណ្តើរជនរងគ្រោះទាំងខ្សែរៗ និងក្អែក ឃើញគុក ព្រមទាំងសម្រែកគេវាយ អ្នកជាប់គុក ឃើញរណ្តៅ ធ្លាប់សម្ងាប់ កប់សាកសព ។

យើងថត សម្ភាសន៍ ទុកឯកសារបួច ។

សំដីសាក្សីបានប្រាប់យើងថា នៅឆ្នាំ១៩៧៧ គាត់ឃើញខ្មែរក្រហមបណ្តើរជនរងគ្រោះទាំងខ្សែរៗ តាមផ្លូវមុខផ្ទះគាត់តម្រង់យកទៅសន្តិសុខយកចុងជ្រោយ ទីនោះនៅចុងភូមិ ឆ្ងៃងខាងត្បូង ១ គីឡូម៉ែត្រ ។ មួយខ្សែៗ ១២នាក់ ទៅ ២០នាក់ ទៅ ៣០នាក់ ២ ទៅ ៣ ថ្ងៃ ឃើញម្តងរហូតរាល់ខែ ពី ១៩៧៧-៧៨ ទល់១៩៧៩ ។ គាត់តែងបានឮសម្រែកស្រែកម៉ោង ៦ល្ងាច ៧ល្ងាច ពេលមួយនោះ ឮស្រែកខ្លាំងពេក គាត់លបមើលឃើញគេ (ឃាតករកំពុងដុតដែកបុករុកអ្នកទោសស្រីភេទ គាត់ស្គុតអស់ ស្មារតី ) ។ នេះជាក់ស្តែងពេលនោះគាត់ជាកុមារ។ អាយុ ១១, ១២ ឆ្នាំ ជាង។

<u>ប្រភេទជនរងគ្រោះ</u>

- គេបណ្តើរពាល់ថ្ងៃ យកពីគ្រប់បណ្តាឃុំ សហករណ៍ទូទាំងស្រុក ១៨ ពីព្រោះគុកនោះរបស់ ស្រុក នាសម័យនោះ ។
- គេចោទថាខ្លាំង មាននិន្នាការបង្កប់ដៃក្នុងទាក់ទងខាងក្នុង ខុសសីលធម៌ផ្សេងៗ ដូច្នេះគេ បណ្តើរ នេះ ឃើញមានចាស់ ស្រី ក្មេងតូចៗ ។ មានថ្ងៃខ្លះសុទ្ធតែយុវជន យុវតី ក្មេងៗ ជាកងចល័ត ចងទាំងខ្សែរៗ ។ បើគេចាប់ខ្លី គេស្រាវជ្រាវរកប្រពន្ធ រកកូន ។ ពេលខ្លះគេយករទេះទៅដឹកកូនៗ កូនសិស្ស ដែលគេសម្លាប់ ឪពុកម្តាយរួច ដឹកពេញៗរទេះ ។ (សម្លាប់ ទាំងចាស់និងថ្មី)

<u>ចំនួនរណ្តៅកប់សាកសព នៅចុងជ្រោយនេះ</u>

មាន ៨ម៉ែត្រ បួនជ្រុង, ១០ម៉ែត្រ ទៅ ៣០ម៉ែត្របួនជ្រុង ជំរៅ ៥ម៉ែត្រ ទំលាក់ ៣ លើក ពេញទើបកប់។

យើងពិនិត្យដល់ទីតាំង មាន ១៥ ម៉ែត្រ បណ្តោយ ទទឹង ៣ម៉ែត្រ ជំរៅ ១,៥០ម៉ែត្រ ក៏មាន តូចៗ អាចមានពី ២០០ រណ្តៅ ទៅ ៣០០ រណ្តៅ ។

រណ្តៅធំ ពី ៣០ ទៅ ៤០ រណ្តៅ (ពត៌មានសាក្សី) ។

<u>ការប៉ាន់ស្មានអ្នកស្លាប់</u> : ពី ៧០,០០០ នាក់ ទៅ ១៥០,០០០ នាក់

ទំហំផ្ទៃដីសម្រាប់ ដីដីការណ្តៅមាន១គីឡូម៉ែត្រ បួនជ្រុង កប់ពេញទាំងអស់ ។ (សព្វថ្ងៃព្រៃស្រុប ឬព្រៃបុសរីព្រៃ) ។

ពត៌មានទាំងអស់ខាងលើនេះបានមកពីសាក្សី ២ នាក់ ព្រមទាំងប្រជាជនទាំង ៤ នាក់ ដូចជា :

១- **សែម សឿន** អាយុ ៤២ ឆ្នាំ

២- **រ៉ែន ជាត** អាយុ ៣៨ ឆ្នាំ

៣- **ឌឹម ប៊ុន** អាយុ ៣១ ឆ្នាំ

៤- មេឃុំ **ខ៉ា អ៊ឹម** អាយុ ៥៦ ឆ្នាំ

យើងចុះពិនិត្យផ្ទាល់ទីតាំងគុកសន្តិសុខ ទីតាំងសម្រាប់ យើងឯកភាពការពិតរាយការណ៍គឺសមរម្យតាមការជាក់ស្តែង។ ដូច្នេះយើងរួមគ្នាកាត់តំលៃទៅតាមការជាក់ស្តែង នោះយើងរាប់មិនអស់រណ្តៅសម្រាប់ទេ ច្រើនណាស់ បើត្រូវប្រើពេល១ថ្ងៃ ។ ប្រជាជនទាំង ៣នាក់ លោកមេឃុំនៅភូមិឈើគ្រាច តែម្តង។

ក្រុមការងារស្រាវជ្រាវ បានបញ្ចប់ការងារនៅទីនោះម៉ោង ៨រសៀល ។

## <u>សេចក្តីសន្និដ្ឋានផ្ទាល់</u>

ក្នុងស្រុករលាប្អៀរ សន្តិសុខឆានាល ។ ស្រុកនោះជាស្រុកជាប់ផ្លូវជាតិលេខ ៥ តែក្បែរទីក្រុងកំពង់ ឆ្នាំង ។ ប៉ុន្តែពិនិត្យទីតាំងសម្រាប់មានច្រើនធំៗ និងសំខាន់ៗ ។

យើងចង់បានសាក្សីឲ្យបានច្រើនច្បាស់ៗជាងនេះទៅទៀត ប៉ុន្តែយើងខ្វះពេលវេលាមានទីតាំងធំៗ ដូចជាព្រៃឱ្យាច់សរ យើងមានសាក្សីមិនទាន់ច្បាស់ល្អ ព្រោះទីនោះគ្មានប្រជាជនរស់នៅទេពីមុន និងបច្ចុ ប្បន្ន ប៉ុន្តែយើងដឹងមេឃាតករ ក្រុមឃាតករ នៅរស់ នៅឆ្ងាយ (ខ្វះពេលវេលា) ។

ហើយសាក្សីនាំបង្ហាញ សម្ភាសន៍រួច ថតរួច ទីតាំងនោះគ្រាន់តែជាអ្នកដឹងតៗ និងសំខាន់បានរក ឃើញផ្ទាល់ទីតាំងរណ្តៅ ឆ្ងឹង តែប៉ុណ្ណោះ ។

យើងនៅសេសសល់ទីតាំងខ្លះទៀត ដែលចុះមិនអស់ ហើយដឹងមិនទាន់ច្បាស់លាស់នៅឡើយ គ្រាន់តែដឹងប្រយោល ចាំបាច់ស្វែងរកមេឃុំដែលមានទីតាំង ដើម្បីស្វែងរកនៅពេលខាងមុខ បើមាន កម្មវិធីបន្ត ។

(ចប់ស្រុករលៀប្អៀរ)

## ថ្ងៃទី ២៦-៦-៩៨

## IV- <u>ស្រុកសាមគ្គីមានជ័យ</u>

ថ្ងៃទី ២៦-៦-៩៨ យើងបានធ្វើដំណើរតាមផ្លូវជាតិលេខ ៥ ថយក្រោយមកត្បូង ដល់ទីតាំង ផ្លូវបត់ស្តាំទៅតម្រង់ឆកស្រុកសាមគ្គីមានជ័យ ដល់ខេត្តម៉ោង .... ចំងាយ ៨៨ គីឡូម៉ែត្រ ពីខេត្ត ពីផ្លូវជាតិ ទៅស្រុក ១២ គីឡូម៉ែត្រ ។

<u>ទីតាំងស្រុកសាមគ្គីមានជ័យ</u>

ស្រុកសាមគ្គីមានជ័យ ឋិតនៅខាងត្បូងឈៀងខាងលិច ខេត្តកំពង់ឆ្នាំង ជាតំបន់ភាលរាប សម្បូរ ទៅដោយព្រៃស្ងួប ព្រៃរនាម ព្រៃស្បោត ព្រៃរហោះ ។

<u>ព្រំប្រទល់ស្រុក</u>

- ខាងជើង ទឹកដួសរលាប្អៀរ ខេត្តកំពង់ឆ្នាំង
- ខាងត្បូង ស្រុកខ្គុង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ
- ខាងលិច ថ្ពង កំពង់ស្ពឺ និងទឹកដួសកំពង់ឆ្នាំង
- ខាងកើត ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

- មាន ៩ ឃុំ ៨៩ ភូមិ ចំណុះស្រុក
- មាន ១១,១៨០ គ្រួសារ ។ មានប្រជាជន ៥៦,៣៣៤ នាក់ ក្នុងនោះស្រី ២៩,២៩០ នាក់ ។
- មុខរបរប្រជាជន ធ្វើស្រែ ចំការ កាប់អូស ធ្យូង ឈើ ឡើងត្នោត ។
- សម័យប៉ុល-ពត តំបន់ ៣១ ភូមិភាគបច្ចឹម

• សមរភូមិ-ពត ស្រុក ១២ កំពង់ត្រឡាចលើ ។

**<u>អំពីឥតិហាស</u>**

- សន្តិសុខ នៅបណ្តាឃុំឆ្ងាយ ស្ទាយជុក ក្រាំងលាវ តំបន់ដាច់ស្រយាល មិនធានាថ្ងៃទី ២៥-៦-៩៨ ចូលទីតាំងឃុំស្ទាយជុក ពួកខ្មែរក្រហម ។
- ពត៌មានពីទីតាំងប្រល័យពូជសាសន៍ ទូទាំងស្រុកមាន ៣ ឃុំ ធំៗ សំខាន់ និងបណ្តាឃុំ ផ្សេងៗ ។
- លោកអភិបាលស្រុក **ឈឿន ឈឿន** និងលោក **សឹម ពន** អនុប្រធានការិយាល័យ កសិកម្ម ស្រុកសាមគ្គីមានជ័យ ប្រាប់យើងអំពីទីតាំងទាំងនោះថា :

ក្នុងឃុំស្ទាយជុកមាន

- ដីរស្រុត សន្តិសុខគុក កន្លែងសម្លាប់
- ទីតាំងសម្លាប់ ក្រាំងស្រម៉ ភូមិចាស់
- ច្រកសង្កែ

ទីតាំងទាំងនេះឋិតនៅទិសនីរតីស្រុក ចំងាយពីសាលាស្រុកដល់សាលាឃុំស្ទាយជុក១៦គីឡូម៉ែត្រ ដល់ទីតាំងសម្លាប់ ២០គីឡូម៉ែត្រ ។ (អស្ចារ្យភាពខ្មែរក្រហម)

១- <u>ឃុំក្រាំងលាវ</u>

- <u>សន្តិសុខគុក អកច្រាក់</u> ពាក្យប្រើសព្ទថ្ងៃ, ជំនាវជ្រែងសម័យមុនៗ

- កន្លែងសម្លាប់ ព្រៃឆ្ងាយ ៣ គីឡូម៉ែត្រ ថ្មើរដើង (គ្មានគមនាគមន៍) អស្ចារ្យភាពខ្មែរក្រហម (មិនធានា) ។

ទីតាំងនេះឋិតនៅទិសពាយព្យ សាលាស្រុកចំងាយ ១០ គីឡូម៉ែត្រ ដល់គុកសន្តិសុខគុក ១៣ គីឡូម៉ែត្រ ដល់កន្លែងសម្លាប់ (រថយន្ត) ទៅពីសាលាលេខ៩

គឺ១៨ គីឡូម៉ែត្រ ដល់ទីតាំង សម្ងាប់ ២១ គីឡូម៉ែត្រ ។ (អស្តេរភាព) (ប្រើពេល ២ ថ្ងៃ ទៅបាន) ។

<u>សន្តិសុខមូលដ្ឋានគុកជំទាវជ្រែង</u> : កសាងឡើងឆ្នាំ ១៩៧៦-៧៧-៧៨ រហូតបែកទល់ ១៩៧៥ ពី ១៩៧៧៥-៧៦-៧៧-៧៨ រហូតបែកតែមួង គឺ១៩៧៩ ។

កន្លែងសម្ងាប់ឆ្ងាយពីសន្តិសុខគុកទំទាវជ្រែង ពាគីឡូម៉ែត្រ សាក្សីមិនដឹងឈ្មោះព្រៃនោះឈ្មោះ អ្វី? ។

២- <u>ឃុំពាម</u>

<u>ទីតាំងសម្ងាប់</u> : ភូមិថ្មី ទីតាំងនោះមិនធំដុំទេ ប៉ុន្តែយើងមិនចាប់អារម្មណ៍ដោយសារអស្តេរ ភាព បញ្ហាសន្តិសុខ ។

**<u>អំពីឧត្តមាន របាយការណ៍ពីសាក្សី ៤នាក់</u>**

យើងបានជួបសាក្សីដ៏សំខាន់ ៤នាក់ ដែលលោកចៅហ្វាយស្រុកបានរកអោយយើង អ្នកទាំងនោះ សំខាន់ៗ ធ្លាប់ជាប់គុកដីស្រុត ធ្លាប់ជាសន្តិសុខគុកជំទាវជ្រែង ធ្លាប់ធ្វើសន្តិសុខឃុំ និងជាកងហាររយឃុំ (កងហាររយ) កងចល័ត សហករណ៍ខាងស្បៀង) ។

- ឈ្មោះសាក្សីដែលបានអោយពត៌មានដល់យើង :

  ១- លោក **សឹម ពន** អនុប្រធានការិយាល័យកសិកម្មស្រុក ជាប់គុក ៣ឆ្នាំ នៅ សន្តិ សុខគុកដីស្រុត នាសម័យប៉ុល-ពត ។

  ២- **ម្ជួ ម្យឿន** អាយុ ៥៦ ឆ្នាំ កងហាររយសហករណ៍នៅឃុំស្វាយជុក (ដីស្រុត) សម័យ **ប៉ុល ពត** ។ សព្វថ្ងៃប្រធានភូមិមានពរ ឃុំក្បែងខ្ពស់ ។

  ៣- **គក ហាក់** អាយុ ៤២ ឆ្នាំ នៅភូមិមានពរ ឃុំក្បែងខ្ពស់ ។ សម័យ **ប៉ុល ពត** កងសន្តិសុខគុកជំទាវជ្រែង មានតួនាទីកាន់បញ្ជីជនរងគ្រោះ អ្នកទោសដែលជាប់ គុក អ្នកចាប់សម្ងាប់ ។

សាកសួរទាំងអស់នេះ បានជ្រាប់យើងនូវពត៌មានលំអិតសំខាន់ៗ ដឹងរឿងពិត ពីព្រោះសុទ្ធជាអតីតៈ កម្មាភិបាលប៉ុល-ពត និងអ្នកធ្លាប់ជាប់គុកដល់ទៅ ៣ ឆ្នាំ ទៀតផង ។ (សម្ភាសន៍ និងថតរូប) ។

**<u>ឧត្តមានពីសាក្សី សឹម ឧត</u>** អាយុ ៤៧ ឆ្នាំ

គាត់ជាប់គុកនៅសន្តិសុខគុកដីស្រុត មូលហេតុជាប់ដោយសារពាក្យសម្តីនិយាយដោយសារ មនោសញ្ចេតនាឲ្យប្រជាជនថ្មីដើរកត្រីសាច់ហូប គេថាជ្រៀតជ្រែកដល់គេ .....។ល។ គេក៏ចាប់ដាក់គុក រួចលែងចុងឆ្នាំ ១៩៧៨ ដើមឆ្នាំ ១៩៧៩ ដោយផ្ញាស់ទៅធ្វើត្រីនៅ ខាងកើតខេត្តកំពង់ឆ្នាំង។ ជាប់ពី ១៩៧៧ ដល់ ១៩៧៩ ។

រួចពីគុកដោយសារណាសិរ្សវាយរំដោះ ១៩៧៨-១៩៧៩ ។ ឆ្នាំ១៩៧៩ ចូលមករស់នៅឃុំស្វាយ ជុកវិញ ។

+ <u>ប្រភេទអ្នកជាប់គុកនៅទីនោះគឺ :</u>

<u>អ្នកជាប់គុកទី១</u> : គេចោទថាទាក់ទងខ្មែរសឹរមកពីហាណូយ ដូចជាមានបងប្អូន ធ្វើឥស្សរៈនៅហាណូយ ជាប់ជាបងប្អូន ទោះបីអ្នកនោះស្លាប់ក៏គេយកបងប្អូនសាច់ញាតិ មកសម្លាប់ដាក់ គុកទីនោះដែរ ។

<u>អ្នកជាប់គុកប្រភេទទី២</u> : ជាកម្មាភិបាលខ្មែរក្រហមតែម្តង ជាឧកញ៉ាខ្មែរក្រហម សន្តិសុខក្តី អោយតែខុសឆ្គងសីលធម៌ ឬខុសអ៊ីចឹងក៏ដោយ ក៏យកមកដាក់គុកសម្លាប់ទីនោះដែរ ។

<u>ប្រភេទអ្នកជាប់គុកទី៣</u> :

- មន្ត្រីរដ្ឋការ ស៊ីវិល ឧកញ៉ា ប៉ែអឹម ប៉ូលិស គេញ គយ គ្រូ សាស្ត្រាចារ្យ បញ្ញវន្ត អ្នកចេះដឹង វណ្ណៈអ្នកមាន អភិជន ...។ល។ ពួកនេះគេអោយដកស្នង អោយហូបបបរ គេសួរតាមដានបណ្តើរៗ បើដឹងថា នរណាធ្វើអ្វី បូលិស ឧកញ៉ា ប៉ែអឹម ..។ល។ គេយកមេត្រួសារ ប្រពន្ធ កូន សម្លាប់ផ្តាច់ពូជតែម្តង ។ សម្លាប់ រួចដោះច្រវាក់ចេញ ។

• អស់ពីគុក នាំអ្នកថ្មីចូលទៀត តៗមករហូត ។

ប្រភេទទី៤ : ពួក ១៧មេសា សម្លាប់ឆ្នាំ១៩៧៥-៧៦ ។ ឯពួកកម្លាភិបាលខ្មែរក្រហម គ្នារ៉ា មិនទុកយូរក្នុងគុកទេ ១ថ្ងៃ, ២ថ្ងៃ នាំទៅសម្លាប់តែម្តង ។

កន្លែងសម្លាប់នៅ:

១- ដីរស្រុត នៅឃុំស្វាយជុក សម្លាប់ឆ្នាំ ១៩៧៥ តៗ ទល់ ១៩៧៩ ។

២- ព្រៃទទឹង

៣- ជ្រលងតាពុត

ពួកឃាតករបណ្តើរទាំងខ្សែរៗ សម្លាប់ពេលយប់ ភ្លឺឡើងគេឃើញពួកឃាតករប្រទ្ឆាក់ទៅដោយ ឈាមពេញខ្លួនច្រាណ ដៃ ជើងរ៉ា ។ មុនសម្លាប់ សម្រាតយកខោអាវអស់ ទើបសម្លាប់

+ សាក្សី **សឹម ពន** បន្តែមថា អ្នកដំលៀសចេញពីទីក្រុង កំទេចឆ្នាំ ១៩៧៥ ។

+ ចំនួនរណ្តៅសាកសពជនរងគ្រោះ

- នៅដីរស្រុត ជ្រលងតាពុត ព្រៃទទឹង
- រណ្តៅពី ៧០០ ទៅ ១,០០០ ឬ ១,២០០ រណ្តៅ ខ្មោច ១ កាត់ជាពីរ ដាក់កប់ រួចដាំ ដូងពីលើ បើអស់ ពេញ ទើបដាក់រណ្តៅផ្សេងៗទៀត
- រណ្តៅនិមួយៗ ១នាក់, ២នាក់, ៥នាក់ ក៏មាន ។

ចំនួនអ្នកស្លាប់ : ពី ១២,០០០នាក់ ទៅ ១៣,៥០០ នាក់ ។ (សាក្សីបញ្ជាក់ថា មានតែលើសពីនេះ ទៀត)

+ សាក្សី **ម្ជុ ម៉ឿន** អាយុ ៥៦ ឆ្នាំ សព្វថ្ងៃគណៈកម្មការវត្ត (ន៣) ។ បានប្រាប់យើង ដូចតទៅនេះ :

ទីតាំងសន្តិសុខគុក អកជ្រាក់ ជិតវាជ្រែង ឃុំក្រាំងលា

- កន្លែងសម្ងាប់ឆ្ងាយពីគុក ៣ គីឡូម៉ែត្រ (ព្រៃ)
- មិនស្គាល់ឈ្មោះព្រៃសម្ងាប់ (សួរឃុំ) ។
- សម័យ **ប៉ុល ពត** នៅឃុំក្រាំងលាវ ភូមិមានគាត់មានតួនាទីជាកងចល័ត (កង ហារយ) អ្នកដលិតស្បៀង ។

<u>ពត៌មានពីគាត់</u>

+ <u>ប្រភេទជនរងគ្រោះ</u>

- ១៩៧៣-៧៤-៧៥ ដាក់ឋាហាន **លន់ ណុល** ឋាហានដែលចាប់បាន (ឈ្លើយសឹក) ។ មន្ត្រីរដ្ឋការ ស៊ីវិល គ្រូ បញ្ញវន្ត ប្រជាជនថ្មី និងប្រជាជនចាស់នៅមូលដ្ឋាន អោយតែគេចោទថាមានខ្សែរយៈនិន្នាការជាប់ទាក់ទងខ្សែស្រឡាយ សាច់ញាតិ អ្នកទីក្រុង អ្នកថ្មី ខុស សីលធម៌ ចាប់បញ្ចូលគុកទាំងអស់ ។ ជាពិសេសគេចោទថាចារកម្ម ។
- មុនឆ្នាំ១៩៧៥ គេចោទគ្រូ ឬអ្នកចេះដឹង គេថាចារកម្ម គេសួរចម្លើយ វៃ ឃឺ បើគេសួរស្ទឹ ឆ្លើយហ្នឹង បើឆ្លើយក្លាមៗ គេឈប់វៃ គេយកសម្ងាប់ពេលឆ្លើយរួច អ្នកត្រង់សោះ ក៏ឆ្លើយ ថាធ្វើឋាហានសត្តិ ៥ សត្តិ ២ ឬប៉ូលីស បើមិនឆ្លើយ គេវៃ វៃតាល់តែឆ្លើយ ។

ដូចនេះទីតាំងនេះ ពូ **គក ហាក់** ពីមុនសន្តិសុខនៅអកញ្រាក់ ជំនាវ **ថ្លៃង** គាត់ដឹង ដូច **ម្ចូ ម្សឿង** ដែរ គាត់ជាអ្នកគ្រាប់បញ្ជើដ្ឋាល់ កត់ត្រា អ្នកមកជាប់គុក អ្នកសម្ងាប់ ប៉ុន្តែ ១៩៧៥ គាត់ទៅធ្វើឋាហាន **ប៉ុល ពត** នៅមជ្ឈឹម ភ្នំពេញ ដូច្នេះឯកសារត្រូវប្រគល់អោយអ្នក ក្រោយៗ ។

គាត់ប្រាប់ទីតាំងថា ផ្ទះប្រជាជននៅទីនោះទាំងអស់ ៨០ខ្នង (ឯផ្ទះយកធ្វើជាគុក ៦ផ្ទះ សុទ្ធ តែផ្ទះក្បឿងធំៗ ដាក់អ្នកទោសពេញៗ ពេលសួរចម្លើយរួចម្តងៗ ពី ១២នាក់, ២០នាក់, ៣០នាក់

បណ្តើរយកទៅសម្លាប់ម្តង ព្រៃចំការយ ៣ គីឡូម៉ែត្រ សម្លាប់ ពេលព្រលប់ៗ ។ និងយប់ក៏មាន ។

សាកូរី **ម៊ួច ម៉ឿន** សន្និដ្ឋានស្មានរណ្តៅមិនច្បាស់

សាកូរី **គក ហាក់** ស្មានរណ្តៅមិនច្បាស់

ចំនួនរណ្តៅមិនច្បាស់ (ទៅមិនដល់)

<u>ចំនួនអ្នកស្លាប់</u>

8 ១៩៧៣ - ១៩៧៤ មាន ៣០,០០០ នាក់ ដោយសាកូរី **គក ហាក់** ។

☐ ១៩៧៥ - ១៩៧៩ មាន ៥,០០០ នាក់ ទៅ ៦,០០០ នាក់ ដោយសាកូរី **ម៊ួច ម៉ឿន** ។

សរុប ៣៦,០០០ នាក់ ។

- ពត៌មានបន្ថែមលំអិតមានការសែតថតសំឡេងទុកឯកសារ ។

<u>សាកូរី **សឿ រឿន**</u> អាយុ ៤៩ ឆ្នាំ ។ បានជ្រាបទីតាំងកងមាស

ទីតាំងសម្លាប់តែម្តង

+ <u>ព្រៃកងមាស</u>

ទីនេះគាត់បានឃើញរណ្តៅ ៣ធំៗ មានទទឹង ២ម៉ែត្រ បណ្តោយ ១៥ម៉ែត្រ ជំរៅ ១,៥ម៉ែត្រ ។ គេគាស់រកមាស ឆ្នាំ ១៩៨២-១៩៨៣ ទីនេះគាត់បានឃើញផ្ទាល់ភ្នែក ពេលគេគាស់ គាត់ជាន់ស្មានមានពី ១០០ នាក់ ទៅ ១៥០នាក់ ។

ប្រភេទជនរងគ្រោះ : នៅព្រៃកងមាសនេះគេសម្លាប់ឆ្នាំ ១៩៧០ មក ១៩៧៥ គឺនរណាមិនដើរ តាមពួកខ្មែរក្រហម គេសម្លាប់នៅព្រៃនោះ ។

យើងសោកស្តាយ ដោយយើងមិនអាចទៅដល់ទីតាំងទាំងអស់នោះបាន (អស្តេរភាព សន្តិសុខ) ដូច្នេះមិនអាចដឹងបានអស់ ។ ចំការយ ប៉ុន្តែសុទ្ធតែព្រៃមិនអាចទៅបាន គ្មានផ្លូវគមនាគមន៍ ។

## សេចក្តីសន្និដ្ឋាន

ស្រុកសាមគ្គីមានជ័យនោះ ជាតំបន់នៅឆ្ងាយណាស់ ហើយដូរតែមនាគមន៍ទៅកាន់ទីតាំងសន្តិសុខ គុក កន្លែងសម្ងាប់នៅឆ្ងាយ មិនធានាសន្តិសុខ តាមប្រសាសន៍លោកចៅហ្វាយស្រុកយើងទៅបានទាល់ តែបានប្រាប់គាត់មុន ១ថ្ងៃ, ២ថ្ងៃ នៅទីតាំងនីមួយៗនោះ។ ហើយនៅនោះទៀតសោត អាចដើរ ៦គីឡូម៉ែត្រ ទៅ និង មក ចេញពីទីតាំងសន្តិសុខគុកទៅរកកន្លែងសម្ងាប់ ដើរសុទ្ធតែព្រៃ សូម្បីតែម៉ូតូឌុប ជិះមិនបានដែរ (គ្មាន ផ្លូវ) ។

ហេតុនេះហើយ យើងមិនអាចទៅដល់ទីតាំងបាន យើងមិនបានចុច Computer គួសដែនទី ទីតាំងប្រល័យពូជសាសន៍នោះបានទេ ។

ក៏ប៉ុន្តែយើងមានរបាយការណ៍បញ្ជាក់ពីសាក្សីដ៏សំខាន់ៗ ដូចដែលបានបញ្ជាក់ស្រាប់ខាងដើម យើងខ្វះរូបថតទីតាំងសន្តិសុខគុក កន្លែងសម្ងាប់ ប៉ុន្តែបានរកសាក្សីល្អៗបានខ្លះហើយ ពេលខាងមុខសង្ឃឹមថាយើងរកបានសាក្សីបន្ថែមទៅកន្លែងក្បែរៗនោះ ។ ដូច្នេះជំហានទី១ នេះ ការដឹងបានន្លូវសភាពការណ៍ ស្រុកបានខ្លះៗ ជាមូលដ្ឋានល្អសំរាប់ពេលខាងមុខ ។

គ្រប់ទីតាំងទាំងអស់នេះ សន្តិសុខមិនធានា ចៅហ្វាយស្រុកមិនអនុញ្ញាតនោះ ស្រុកសាមគ្គីមាន ជ័យ ។

ចំពោះស្រុកជលគីរី យើងបារម្ភសន្តិសុខដែរ ពីព្រោះស្រុកកំពង់លែងខាងអាយពួកខ្មែរក្រហម ចូលស្រុកច្រណូក ឯជលគីរីនៅឆ្ងាយជាងកំពង់លែងទៅទៀត ។

ដូច្នេះសរុបរួមក្នុងបណ្តាស្រុកទាំង៨ ដែលបានចុះក្នុងខេត្តកំពង់ឆ្នាំងក្រុមយើងបានខិតខំពុះពារ តស៊ូ អំណត់អត់ធន ទោះបីកាត់ព្រៃស្ងាត់ កាត់វាលយើងប្រឹងប្រែង ទោះបីចោរកម្ម ឬន់ប្រដាប់អាវុធ មានខ្លះៗ ក៏យើងហ៊ានជំនះ ។

ប៉ុន្តែបើមូលដ្ឋានហាមឃាត់ ហើយពេលវេលាប្រកបដោយតក់ក្រហល់ និងគ្រោះថ្នាក់ យើងគួរតែ ពិចារណា ។ ម្យ៉ាងទៀតដូរទីកដូរនេះមិនអំណោយផលដល់យើងប៉ុន្មានទេ

រយៈ១ថ្ងៃ ១ស្រុក ដូចកំពង់ លែង ជលគីរី ល្ងាចពីម៉ោង ១៨:០០ យើងបារម្ភពុះភ្លៀង ។

ភ្នំពេញ,ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ១៩៩៨

អ្នកសរុបរបាយការណ៍

**ស៊ុន ឃិន**